**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស(អ.ប.ជ៧៥)

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គបុរេជំនុំជម្រះ

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១០

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 28-Oct-2010, 14:29
CMS/CFO: Kau Keoratanak

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## សារណាបន្ថែមទៅលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ

---

| ដាក់ដោយ៖ | ផ្ញើជូន៖ | ផ្ញើជូន៖ |
|---|---|---|
| **សហមេធាវីរបស់លោក អៀង សារី** | **អង្គបុរេជំនុំជម្រះ** | **សហព្រះរាជអាជ្ញា** |
| លោក អាង ឧត្តម | ចៅក្រម ប្រាក់ គឹមសាន | លោកស្រី ជា លាង |
| លោក Michael G. KARNAVAS | ចៅក្រម ន៍យ ថុល | លោក Andrew CAYLEY |
| | ចៅក្រម ហួត វុទ្ធី | |
| | ចៅក្រម Catherine MARCHI-UHEL | **ក្រុមមេធាវីការពារក្ដីទាំងអស់** |
| | ចៅក្រម Rowan DOWNING | |

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី") សូមដាក់សារណាបន្ថែមទៅក្នុងបណ្តឹងឧទ្ធរណ៍របស់គាត់ប្រឆាំងនឹងដីកាដំណោះស្រាយ[1]។ សារណានេះផ្តល់នូវការគាំទ្របន្ថែមទៀតដល់ការអង្កេតបឋមដែលធ្វើឡើងក្នុងបណ្តឹងឧទ្ធរណ៍នេះថា អវតក គឺជាតុលាការជាតិរបស់ប្រទេសកម្ពុជា[2]។ ភស្តុតាងនេះមិនអាចរកបានទេ នៅពេលមេធាវីការពារក្តីបានដាក់បណ្តឹងឧទ្ធរណ៍នេះ ។

១. កាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១០ លោក បាន គីមូន អគ្គលេខាធិការអង្គការសហប្រជាជាតិ បានចូលរួមកិច្ចប្រជុំនៅ អវតក ។ នៅក្នុងកិច្ចប្រជុំនោះ លោក បាន គីមូន បានបញ្ជាក់ថា៖ "អវតក មានរចនាសម្ព័ន្ធប្លែកពីតុលាការដទៃទៀតដែលគាំទ្រដោយអង្គការសហប្រជាជាតិ ។ អវតក គឺជាតុលាការកម្ពុជា ដែលស្ថិតនៅក្នុងយុត្តាធិការកម្ពុជាយ៉ាងពេញលេញ ។ ប៉ុន្តែតុលាការនេះមានការចូលរួមពីអន្តរជាតិ និងទទួលការគាំទ្រពីអង្គការសហប្រជាជាតិ[3]"។

២. កិច្ចប្រជុំនេះក៏បានចូលរួមផងដែរដោយឯកឧត្តមឧបនាយករដ្ឋមន្ត្រី បណ្ឌិត សុខ អាន លោកស្រី Patricia O' Brien ដែលជាអគ្គលេខាធិការរងទទួលបន្ទុកកិច្ចការច្បាប់ និងជាមេធាវីសម្រាប់អង្គការសហប្រជាជាតិ ព្រមទាំងចៅក្រម និងបុគ្គលិក អវតក ជាច្រើននាក់ទៀត។ គ្មាននរណាម្នាក់បានជំទាស់ទៅនឹងសេចក្តីថ្លែងការណ៍របស់លោក បាន គីមូន ឡើយ។

សូមចៅក្រមអង្គបុរេជំនុំជម្រះទទួលយកសារណាបន្ថែមនេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **២៨** ខែ **តុលា** ឆ្នាំ **២០១០**

**អាង ឧត្តម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**

---

[1] ករណីលោក អៀង សារី, សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ៧៥), បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០, ឯកសារ D427/1/6, ERN:00617486-00617631។

[2] ដូចជើងទំព័រខាងលើ, កថាខណ្ឌទី៨ ដល់២០។

[3] ការថ្លែងរបស់លោក បាន គីមូន អគ្គលេខាធិការអង្គការសហប្រជាជាតិ ផនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១០, មជ្ឈមណ្ឌលព័ត៌មានរបស់អង្គការសហប្រជាជាតិ សូមចូលទៅកាន់គេហទំព័រ http://www.un.org/apps/news/infocus/sgspeeches/statements _full.asp?statID=993.